សំរង់ព័ត៌មានប្រចាំសប្តាហ៍

# ស្ថានភាពកុមារនៅកម្ពុជា

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

ឆ្នាំទី១ លេខ ៥ ថ្ងៃទី១៩ ដល់ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៥

មាតិកា ទំព័រ

៨ខែដើមឆ្នាំ២០០៥មានកុមារឈឺ ដោយជំងឺគ្រុនឈាមជាង៤៣០០........១

រឿងរ៉ាវចាប់រំលោភគួរឱ្យភ្ញាក់ផ្អើល ក្មេងប្រុស១១ឆ្នាំចាប់១០ឆ្នាំឱ្យ..........២

សិស្សសាលាអាយុ១៤ឆ្នាំក្លាយជា អ្នកទោសពីបទចាប់ក្មេងស្រី...........៣

ក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ឃុំខ្លួន ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ.........៤

ម្តាយចិត្តស្យាយកទារកពិការខុស ខ្នាតមកបោះបង់ចោល.................៤

ជនជាតិភាគតិចរស់នៅមណ្ឌលគីរី ភាគច្រើនរៀនត្រឹមថ្នាក់បឋមសិក្សា......៥

កុមារនៅភូមិឡមិនមានសាលា សំរាប់ចូលរៀន.......................៦

បីឆ្នាំចុងក្រោយនេះស្ត្រីខ្មែរគេជួញ ដូរនៅម៉ាឡេស៊ី.......................៧

## ៨ខែដើមឆ្នាំ២០០៥មានកុមារឈឺដោយជំងឺគ្រុនឈាម ជាង៤៣០០ករណីស្លាប់៦៨នាក់

មន្ត្រីមជ្ឈមណ្ឌលជាតិកម្ចាត់ជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្របាននិយាយថា រយៈពេល៨ខែក្នុងឆ្នាំ២០០៥នេះ មានកុមារចំនួនជាង៤៣០០ករណីឈឺដោយជំងឺគ្រុនឈាម ក្នុងនោះស្លាប់ចំនួន៦៨ករណី។ តួលេខនេះមានលក្ខណៈល្អប្រសើរជាងកាលពីបណ្តាឆ្នាំកន្លងមក។

លោកវេជ្ជបណ្ឌិតងាន់ ចាន់ថា អនុប្រធានមជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រនៃក្រសួងសុខាភិបាលមានប្រសាសន៍ឱ្យដឹងនៅព្រឹកថ្ងៃទី១៧ សីហា ២០០៥ នេះថា ករណីស្លាប់កុមារដោយជំងឺគ្រុនឈាមភាគច្រើនដោយសារភាពយឺតយ៉ាវរបស់ឪពុកម្តាយក្នុងការនាំកូនមកមន្ទីរពេទ្យ ឬសេវាសុខភាពមូលដ្ឋាន ហើយករណីខ្លះទៀតកុមារស្លាប់ដោយសារឪពុកម្តាយព្យាបាលកូនខ្លួនដោយខ្លួនឯងផ្ទាល់ គឺការប្រើប្រាស់ថ្នាំមិនបានពិគ្រោះជាមួយគ្រូពេទ្យជំនាញ។

លោកបន្តថា អត្រាស្លាប់កុមារឆ្នាំនេះបើប្រៀបធៀបជាមួយឆ្នាំកន្លងទៅមានតិចជាងពាក់កណ្តាល។ ក្នុងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធជំងឺនេះ កម្មវិធីជាតិប្រយុទ្ធជំងឺគ្រុមឈាមបាននិងកំពុងដាក់អាបេតជូនប្រជាពលរដ្ឋនៅលើខេត្តក្រុងចំនួន៧ ដូចជាក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ចាម សៀមរាប កំពង់ឆ្នាំង បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដោយខេត្តនីមួយៗការដាក់អាបេតត្រូវចំណាយពេលពីរសប្តាហ៍។ អាបេតដាក់លើកទី២មានចំនួន៦០តោន។

លោកបានបន្តទៀតថា អាបេតទាំងនោះបានទទួលការឧបត្ថម្ភពីក្រសួងសុខាភិបាល និងការឧបត្ថម្ភថវិកាសំរាប់ចុះបំពេញការងារដោយធនាគារពិភពលោក(WHO)។ ការដាក់អាបេតលើកទី១កាលពីពេលកន្លងមកចំណាយអស់អាបេតចំនួនជាង៦០តោនផងដែរ។ បច្ចុប្បន្នខេត្តក្រុងដែលកំពុងរងគ្រោះដោយជំងឺគ្រុនឈាមច្រើនជាងគេមានខេត្តបន្ទាយ

មានជ័យ កំពង់ស្ពឺ កំពង់សោម និងខេត្តកំពង់ធំ។ ខេត្តបន្ទាយមានជ័យមានស្រុកចំនួន៥ដែលមានជំងឺគ្រុនឈាមកើនឡើងគួរកត់សំគាល់ដូចជាស្រុកមង្គលបុរី ព្រះនេត្រព្រះ ថ្មពួក ស្វាយចេក និងស្រុកអូរជ្រៅ។ បច្ចុប្បន្នអង្គការ CARE , Health Net និងអង្គការRachaកំពុងចុះដាក់អាបេត និងធ្វើការអប់រំប្រជាជនពីគ្រោះថ្នាក់ដោយសារជំងឺនេះ។ ខេត្តកំពង់ស្ពឺមានស្រុកចំនួន៣ដែលមានអត្រាជំងឺគ្រុនឈាមខ្ពស់គឺស្រុកច្បារមនឧដុង្គ និងស្រុកគងពិសី។ កំពង់សោមមានខណ្ឌមិត្តភាព វាលរេញ ស្ទឹងហាវ និងតំបន់ទំនប់រលក។ ចំណែកខេត្តកំពង់ធំ ស្រុកស្ទឹងសែន និងស្រុកប្រាសាទសម្បូរណ៍ក៏កំពុងរងការកំរាមកំហែងដោយសារជំងឺនេះផងដែរ។ នៅតាមបណ្តាមន្ទីរពេទ្យនានានៅភ្នំពេញអត្រាជំងឺគ្រុនឈាមបានកំពុងមានការកើនឡើង ប៉ុន្តែមិនមានអ្វីគួរឱ្យព្រួយបារម្ភទេ ដោយមួយថ្ងៃមានកុមារពី៥ទៅ៨នាក់បានចូលសំរាកក្នុងមន្ទីរពេទ្យកុមារជាតិ នេះបើតាមការបញ្ជាក់ពីនាយកមន្ទីរពេទ្យនៅព្រឹកថ្ងៃទី១៧ សីហា ២០០៥។

លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត ឈួ អ៊ីម៉េង នាយកមន្ទីរពេទ្យកុមារជាតិបានបន្តឱ្យដឹងទៀតថាដោយសាររដូវប្រាំងអូសបន្លាយយូរ យើងមិនឃើញសញ្ញាគួរឱ្យព្រួយបារម្ភរបស់ជំងឺនេះទេ ប៉ុន្តែពេលនេះមេឃចាប់ផ្តើមធ្លាក់ភ្លៀងច្រើន ដូច្នេះយើងកំពុងតាមដានការវិវត្តន៍នៃជំងឺនេះ។ មន្ទីរពេទ្យកំពុងបង្កើនគុណភាពពង្រឹងសមត្ថភាពបុគ្គលិកដើម្បីកាត់បន្ថយអត្រាស្លាប់របស់កុមារឱ្យស្ថិតនៅក្នុងអត្រាទាបបំផុត។

លោកវេជ្ជបណ្ឌិតងាន់ ចាន់ថា បានបន្តអំពាវនាវឱ្យប្រជាពលរដ្ឋរួសរាន់នាំកូនមកមន្ទីរពេទ្យនៅពេលកូនមានអាការៈក្តៅខ្លួនខុសពីធម្មតា ឧស្សាហ៍លាងពាង និងអនាម័យជុំវិញផ្ទះសម្បែងឱ្យបានស្អាតជាប់ជាប្រចាំ។ បើប្រជាជនដែលទទួលបានអាបេតកុំភ្ញាក់ផ្អើលអី ព្រោះការដាក់អាបេតលើកនេះមិនមានវេចខ្ចប់នោះទេ គឺមន្ត្រីសុខាភិបាលដួសដាក់ពាងទឹកតែម្តងប៉ុន្តែវាមានប្រសិទភាពរយៈពេល៣ខែដូចគ្នា និងមិនមានប៉ះពាល់ដល់សុខភាពនោះឡើយ៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៥៧*
*ថ្ងៃទី ១៩_០៨_០៥*

# រឿងរ៉ាវចាប់រំលោភគួរឲ្យភ្ញាក់ផ្អើលក្មេងប្រុស១១ឆ្នាំចាប់១០ឆ្នាំឲ្យ៩ឆ្នាំរំលោភ

រឿងរ៉ាវហួសចិត្តពេកណាស់ដែលព័ត៌មានពីការរំលោភមួយបានកើតឡើងស្ទើរតែមិនជឿ ព្រោះអ្នកប្រព្រឹត្ត និងអ្នករងគ្រោះជាអនីតិជន។ ទោះបីជាការរំលោភនោះវាមិនទាន់ឈានទៅដល់ផលប៉ះពាល់ធ្ងន់ធ្ងរក្តី តែភាពកំរោលនៃតណ្ហាដែលដុតរោលកូនក្មេងមិនទាន់នឹងដឹងអីផងនោះជាប្រការអាស្រូវពេកណាស់ ហើយសង្ឃឹមថាអ្នកអាណាព្យាបាលកូនចៅប្រុសស្រីគប្បីយកចិត្តទុកដាក់ណែនាំអប់រំកូនៗរបស់ខ្លួនផងដែរ មិនត្រូវបណ្តោយនោះទេ ព្រោះថាបញ្ហាធ្ងន់ធ្ងរនឹងកើតឡើងប្រសិនបើមិនមានការស្តីប្រដៅឱ្យមានប្រសិទ្ធិភាពនោះទេ។

រឿងរ៉ាវដែលត្រូវអត្ថាធិប្បាយខាងក្រោមនេះគឺក្មេងប្រុសអាយុ១១ឆ្នាំចាប់ក្មេងស្រីអាយុ១០ឆ្នាំឱ្យក្មេងប្រុសអាយុ៩ឆ្នាំរំលោភ។ ដោយការគំរាមឱ្យក្មេងស្រីនោះខ្លាចគ្មានអ្វីក្រៅពី« ខ្មោចលងទេ» ព្រោះការធ្វើសកម្មភាពមិនគប្បីនេះគឺនៅពេលយប់។ តាមអ្នកឆ្លើយឆ្លងព័ត៌មានប្រចាំខេត្តកំពង់ធំបានរាយការណ៍ឱ្យដឹងថា កាលពីវេលាម៉ោង៩យប់ ថ្ងៃទី១៥ សីហា ២០០៥ នៅមុខផ្សារចាស់នៅឃុំកំពង់ក្របៅស្រុកស្ទឹងសែនមានក្មេងៗចំនួន៣នាក់ក្នុងនោះមានក្មេងស្រីម្នាក់អាយុ១០ឆ្នាំត្រូវក្មេងប្រុសអាយុ១១ឆ្នាំចាប់ឱ្យក្មេងប្រុសអាយុ៩ឆ្នាំរំលោភរហូតបានសំរេចពីរដង។

លោកមេភូមិប្រាប់ថា គាត់ដឹងរឿងនេះដោយសារតែព្រឹកឡើងក្មេងស្រីរងគ្រោះបានប្រាប់ម្តាយថា យប់មិញមានក្មេងប្រុស២នាក់ចាប់រំលោភនាង ទើបម្តាយកុមារីរងគ្រោះទៅប្រាប់ឪពុកម្តាយក្មេងប្រុសទាំង២ ហើយក្មេងប្រុសទាំង២នាក់បានសារភាពថាខ្លួនពិតជាបានប្រព្រឹត្តអំពើអាសអាភាសនោះមែន។ ភ្លាមនោះឪពុកម្តាយក្មេងប្រុសទាំង២ដេញវាយកូនយំផ្អើលពេញភូមិ។

លុះព្រឹកឡើងថ្ងៃទី១៧ សីហា ២០០៥ ប៉ូលីសឃុំរដ្ឋបាលកំពង់ក្របៅបានកោះហៅឪពុកម្តាយនាំក្មេងទាំង៣នាក់មកធ្វើការសាកសួរ ពេលនោះក្មេងប្រុសអាយុ១១ឆ្នាំបានរៀបរាប់ថា ពួកគេទាំង៣នាក់នៅផ្ទះក្បែរគ្នាបាននាំគ្នាទៅ

មើលទូរទស្សន៍ផ្ទះគេនៅក្បែរផ្សារចាស់។ លុះមើលចប់រឿងចិនវេលាម៉ោង៩យប់ ដោយឃើញខែភ្លឺ គេក៏បបួលគ្នាមកលេងនៅមុខផ្សារចាស់ ស្រាប់តែក្មេងប្រុសអាយុ៩ឆ្នាំនិយាយប្រាប់ក្មេងស្រីអាយុ១០ឆ្នាំថា ឱ្យអញសុំ...បន្តិចមកបើមិនឱ្យអញទេប្រយ័ត្នខ្មោចលង។ ដោយយប់ស្ងាត់ក្មេងស្រីរងគ្រោះខ្លាចក៏ដើរអែបជាប់ក្មេងប្រុសទាំងពីរនាក់ ហើយក៏ត្រូវក្មេងប្រុសអាយុ១១ឆ្នាំចាប់ក្មេងស្រីផ្ដួលលើគ្រែក្បែរនោះឱ្យក្មេងប្រុសអាយុ៩ឆ្នាំរំលោភព្រមទាំងគំរាមថា បើហ៊ានស្រែកពួកអញនឹងរត់ចោលឱ្យខ្មោចលងហើយ។ ពេលនោះក្មេងស្រីរងគ្រោះភ័យពេកក៏នៅស្ងៀម។ ក្មេងប្រុសល្មើសអះអាងថា គេរំលោភបានតែ២ដងទេ ហើយម្ដងៗគ្មានបានការអីទេ។ ចំណែកក្មេងប្រុសអាយុ១១ឆ្នាំសមគំនិតបានឆ្លើយបដិសេធថា ខ្លួនមិនបានចាប់រំលោភទេ គ្រាន់តែចាប់ដៃនាងកុំឱ្យរើបំរះប៉ុណ្ណោះ។

ក្រោយពីបានកសាងសំនុំរឿងហើយប៉ូលិសបានធ្វើការណែនាំដល់ឪពុកម្ដាយក្មេងៗទាំងនោះកុំឱ្យបណ្ដែតបណ្ដោយកូនរបស់ខ្លួនដើរលេងពេលយប់ ជាពិសេសកូនស្រី។

ពាក់ព័ន្ធនឹងករណីខាងលើ លោកឈុន លីមខន ព្រះរាជអាជ្ញារងអមតុលាការខេត្តបានឱ្យដឹងថា ចំពោះក្មេងៗដូចគ្នាដែលមានអាយុក្រោម១៣ឆ្នាំពុំទាន់មានទោសទេ ហើយក៏មិនមែនលើកទឹកចិត្តឱ្យក្មេងៗទាំងនេះប្រព្រឹត្តអំពើអាសអាភាសអនាចារបែបនេះដែរជាពិសេសក្មេងទាំងនេះ គឺស្ថិតក្នុងបន្ទុកឪពុកម្ដាយដែលត្រូវខិតខំអប់រំថែទាំកូនរបស់ខ្លួនកុំឱ្យដើរលេងយប់ ហើយត្រូវជំរុញកូនរបស់ខ្លួនឱ្យបានចូលសាលារៀនសូត្រឱ្យបានគ្រប់ៗគ្នា៕

*ដកស្រង់ចេញពី កោះសន្តិភាព លេខ៥៥០៩*
*ថ្ងៃទី១៩_០៨_០៥*

---

# សិស្សសាលាអាយុ១៤ឆ្នាំក្លាយជាអ្នកទោសពីបទចាប់ក្មេងស្រីអាយុ៧ឆ្នាំរំលោភ

ក្មេងប្រុសអាយុ១៤ឆ្នាំមួយរូបដែលកំពុងតែសិក្សាបានក្លាយជាអ្នកទោសពីបទចាប់ក្មេងស្រីអាយុ៣ឆ្នាំម្នាក់រំលោភសេពសន្ថវៈ ហើយត្រូវឪពុកម្ដាយក្មេងស្រីរងគ្រោះប្ដឹងមកសមត្ថកិច្ច។

ក្មេងប្រុសខាងលើត្រូវបានសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកសៀមរាបឃាត់ខ្លួននៅថ្ងៃទី២៣ សីហា ២០០៥ កន្លងទៅនេះ។

លោកអនុសេនីយ៍ត្រីសារុន សំអឿន នាយកផ្នែកនគរបាលព្រហ្មទណ្ឌនៃអធិការនគរបាលស្រុកសៀមរាប និយាយប្រាប់រស្មីកម្ពុជានៅរសៀលថ្ងៃទី២៤ សីហា ២០០៥ថា ក្មេងប្រុសជាប់ចោទឈ្មោះឧ.ស.ស.ប អាយុ១៤ឆ្នាំ ជាសិស្សថ្នាក់ទី៤នៃបឋមសិក្សាបន្ទាយចាស់ មានទីលំនៅភូមិដកពោធិ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប។

លោកបន្តទៀតថា ករណីរំលោភសេពសន្ថវៈនេះ កើតឡើងនៅម៉ោង៧យប់ថ្ងៃទី១៧ សីហា ២០០៥មកម្ល៉េះ ប៉ុន្តែម្ដាយក្មេងស្រីរងគ្រោះទើបតែមកប្ដឹងនៅថ្ងៃទី២៣ សីហា ២០០៥នេះ។

បើតាមការបញ្ជាក់ពីសមត្ថកិច្ចនគរបាលថា កាលពីយប់ថ្ងៃកើតហេតុជនជាប់ចោទបាននាំក្មេងស្រីរងគ្រោះឈ្មោះស.ម៉រស់នៅផ្ទះជាប់គ្នាទៅដើរលេងក្រៅផ្ទះ ហើយនាំក្មេងស្រីរងគ្រោះទៅដីឡូត៍មួយនៅចំងាយប្រមាណ៦០ម៉ែត្រពីផ្ទះ ហើយក៏ធ្វើសកម្មភាពចាប់រំលោភតែមិនបានសំរេច ព្រោះក្មេងនោះឈឺហើយស្រែកយំពេក។ ក្រោយមកក្មេងជាប់ចោទបាននាំក្មេងស្រីមកផ្ទះវិញ ក៏ត្រូវក្មេងស្រីរងគ្រោះប្រាប់ម្ដាយរបស់នាងនៅយប់នោះ។

មន្ត្រីនគរបាលបញ្ជាក់ថាក្រោយពីដឹងរឿងភ្លាមៗគ្រួសារទាំងពីរក៏ធ្វើការសម្រុះសម្រួលគ្នាអស់ជាច្រើនថ្ងៃ តែរកដំណោះស្រាយមិនត្រូវ លុះដល់ថ្ងៃទី២៣ សីហា ម្ដាយក្មេងស្រីក៏ប្ដឹងនគរបាលតែម្ដង។

បើតាមសំដីសារភាពរបស់ក្មេងជាប់ចោទថា រូបគេពិតជាបានចាប់ក្មេងស្រីរំលោភពិតមែន តែមិនបានសំរេចឡើយ ព្រោះក្មេងស្រីយំខ្លាំងពេក។

នគរបាលស្រុកសៀមរាបបាននិយាយថា ក្មេងប្រុសជាប់ចោទបានបញ្ជូនទៅការិយាល័យនគរបាលជួញដូរផ្លូវភេទរួចហើយកាលពីព្រឹកថ្ងៃទី២៤ សីហា ២០០៥ ដើម្បីស្រាវជ្រាវបន្ថែម និងកសាងសំណុំរឿងទៅតុលាការខេត្តសៀមរាបនៅថ្ងៃបន្ទាប់៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៦២*
*ថ្ងៃទី២៥_០៨_០៥*

# ក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ឃុំខ្លួនពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ

ក្មេងប្រុសម្នាក់ដែលបានចាប់ដៃក្មេងស្រីអាយុ១០ឆ្នាំបម្រុងចាប់រំលោភពេលកំពុងរត់លេងបិតពួននៅភូមិលេខ៦ ឃុំស្វាយប្រទាល ស្រុកស្អាង ត្រូវតុលាការខេត្តកណ្ដាលសំរេចចេញដីការឃុំខ្លួនដាក់ពន្ធនាគារជាបណ្ដោះអាសន្នពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ។

កាលពីព្រឹកថ្ងៃទី២២ សីហា ២០០៥ សមត្ថកិច្ចប៉ូលិសប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តកណ្ដាល បានបញ្ជូនក្មេងប្រុសម្នាក់ឈ្មោះអ.ស.អ អាយុ១៥ឆ្នាំ រស់នៅឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាលមកអយ្យការអមតុលាការដើម្បីធ្វើការសាកសួរទៅតាមនីតិវិធីច្បាប់។ ចំណែកក្មេងស្រីរងគ្រោះមានឈ្មោះថា ស.ម អាយុ១០ឆ្នាំ រស់នៅឃុំជាមួយជនល្មើស។

នៅចំពោះមុខតុលាការក្មេងប្រុសរូបនោះបានឆ្លើយបដិសេធថាគេអត់បានចាប់ក្មេងស្រីរងគ្រោះនោះរំលោភដូចគេចោទប្រកាន់ទេ គេគ្រាន់តែចាប់ដៃក្មេងនោះតែប៉ុណ្ណោះ នៅពេលគេដើរទៅបត់ជើងធំនៅដីឡូត៍មួយកន្លែងក្បែរផ្ទះក្មេងស្រីរងគ្រោះ។

ក្មេងប្រុសរូបនេះបញ្ជាក់ទៀតថា នៅវេលាម៉ោង១៨ និង៣០នាទីយប់ថ្ងៃទី១៧ សីហា ២០០៥ បន្ទាប់ពីគេឈប់លេងបិតពួនហើយគេបានទៅបត់ជើងធំនៅដីឡូត៍ ហើយក្មេងស្រីក៏ដើរទៅតាមពីក្រោយ គេក៏បានចាប់ក្មេងស្រីនោះមែនតែមិនមានបំណងចាប់រំលោភទេ។

យោងតាមរបាយការណ៍ប៉ូលិសស្រុកស្អាងបញ្ជាក់ថា មុនពេលកើតហេតុមានក្មេងៗប្រុសស្រីជាច្រើនបាននាំគ្នាលេងបិតពួន នៅពេលគេឈប់លេង ក្មេងស្រីរងគ្រោះបានដើរទៅព្រៃខាងជើងចំងាយ១០ម៉ែត្រដើម្បីរកកន្លែងបត់ជើង ហើយក៏បានជួបក្មេងប្រុសឈ្មោះអ.ស.អ កំពុងបត់ជើងនៅទីនោះដែរ។ ពេលនោះគេក៏ចាប់ដៃក្មេងស្រីស.ម មកក្បែរដីល្បាប់បាំងគុម្ពក្រវាន់បំរុងរំលោភសេពសន្ថវៈ។ ពេលនោះម្ដាយក្មេងស្រីរងគ្រោះស្រែកហៅរកកូនស្រីរបស់គាត់ ពេលនោះស្រាប់តែឃើញឈ្មោះ«អ.ស.អ»រត់ចេញពីកន្លែងកើតហេតុបាត់ទៅ។ រួចទើបឃើញកូនស្រីរងគ្រោះដើរចេញតាមក្រោយ ដោយមានការសង្ស័យឪពុកម្ដាយបានសួរកូនស្រីគាត់ថាមកពីណា ហើយនាងបានឆ្លើយប្រាប់ឪពុកម្ដាយនាងថាឈ្មោះអ.ស.អ ចាប់រំលោភ។ ពេលឮកូនស្រីប្រាប់ពីរឿងហេតុហើយ ឪពុកម្ដាយក្មេងស្រីរងគ្រោះក៏ទៅប្រាប់ឪពុកម្ដាយក្មេងប្រុសអំពីរឿងហេតុដែលកើតឡើង។ លុះដល់ព្រឹកថ្ងៃទី១៨ សីហា ឪពុកម្ដាយក្មេងស្រីរងគ្រោះក៏ដាក់ពាក្យបណ្ដឹងទៅនគរបាលស្រុកស្អាងពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ។ ក្រោយមកប៉ូលិសធ្វើការឃាត់ខ្លួនក្មេងប្រុសរូបនេះនៅព្រឹកថ្ងៃទី១៩ សីហាបញ្ជូនមកអធិការដ្ឋាននគរបាលដើម្បីសាកសួរ។

បន្ទាប់ពីបានពិនិត្យទៅលើសំណុំរឿង និងការសាកសួរក្មេងប្រុសរួច លោកឆេង ផាត់ ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្ដាល ផ្ដើមធ្វើការចោទប្រកាន់ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ រួចបញ្ជូនសំណុំរឿងនេះទៅឱ្យលោកយន សុកល ជាចៅក្រមស៊ើបអង្កេតចាត់ការបន្ត បន្ទាប់មកលោកចៅក្រមសំរេចចេញដីកាឃុំខ្លួនជាបណ្ដោះអាសន្នដើម្បីរង់ចាំការស៊ើបអង្កេតបន្តទៀត៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៦១*
*ថ្ងៃទី២៤_០៨_០៥*

# ម្ដាយចិត្តឫស្សាយកទារកពិការខុសធ្មាតមកបោះបង់ចោល

ទារកពិការដ៏អភ័ព្វដែលទើបនឹងកើតបានអាយុពី៥ទៅ៧ថ្ងៃប៉ុណ្ណោះ ត្រូវបានម្ដាយចិត្តដាច់យកមកដាក់ចោលនៅលើបង់មួយ នៅតាមសួនច្បារផ្លូវភ្លោះមុខមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ដោយគ្មានក្ដីអាណិតអាសូរដល់កូនរបស់ខ្លួនបន្តិចសោះ នៅវេលាម៉ោង៨យប់ថ្ងៃទី១៦សីហា២០០៥។

ទារកអភ័ព្វដែលត្រូវគេបោះបង់នេះ គឺជាទារកពិការដៃ និងជើង ភេទប្រុស អាយុទើបតែបាន៥ទៅ៧ថ្ងៃប៉ុណ្ណោះ មានដងខ្លួនល្អស្អាតធម្មតា តែម្រាមដៃម្រាមជើងជាប់គ្នាហាក់ដូចជាមនុស្សដែលត្រូវភ្លើងឆេះកំបុតម្រាមដៃជើងអស់អីចឹង។ បើយើងពិនិត្យមើលម្រាមជើងរបស់ទារកនេះមានម្រាមនិងក្រចកធម្មតា តែផ្នែកខាងក្រោមនៃបាតជើងមានសាច់ជាប់មិនអាចលាតបាន រីឯម្រាមដៃក៏

ដូច្នោះដែរ។ ចំណែកក្បាលរបស់ក្មេងនោះមានសភាពពយខ្លាំងមកផ្នែកខាងមុខ។

ទារកនេះមានមនុស្សចោមរោមមើលយ៉ាងច្រើន ប៉ុន្តែគ្មានជនណាម្នាក់ជួយក្មេងនេះ ព្រោះពួកគេមើលឃើញទារកនេះពិការដៃជើងទើបពួកគេមិនរវល់ គឺគ្រាន់តែបានឈរមើលប៉ុណ្ណោះ។ ជាសំណាងល្អ មាននារី២នាក់ដោយមានការអាណិតខ្លាំងពេក ខ្លាចទារកនេះត្រូវសត្វយាយី និងខ្លាចទារកនេះស្លាប់ដោយសារមូសខាំ ឬការស្រេកឃ្លានដោយគ្មានទឹកដោះបៅ ទើបនារីទាំង២នាក់នោះសំរេចជួយសង្គ្រោះទារកនោះជាបណ្តោះអាសន្នមួយយប់សិនទំរាំដល់ភ្លឺឡើងចាំគិតទៀត ព្រោះពេលនេះយប់ទៅហើយបើមិនជួយក្មេងនោះនឹងស្លាប់ដោយសារការស្រេកឃ្លានទឹកដោះបៅមិនខាន។

នារីចិត្តធម៌ទាំងពីរនាក់ដែលបានជួយក្មេងនោះឈ្មោះលៀង ស្រីពៅ អាយុ២៥ឆ្នាំ និងម្នាក់ទៀតឈ្មោះ មឿក ពេជ្រ អាយុ២៨ឆ្នាំ បច្ចុប្បន្នស្នាក់នៅក្រោយផ្សារបឹងឈូកខេត្តបាត់ដំបង។

នារីទាំងពីរនាក់បានប្រាប់កម្ពុជាថ្មីថា នៅក្រោយពេលពួកគេទាំងពីរនាក់ញ៉ាំចំណីរួច បានជិះម៉ូតូដើរលេង ក៏ជួបប្រទះនឹងហេតុការណ៍នោះនៅវេលាម៉ោងជិត៩យប់ ក្មេងនេះស្រែកឃ្លានយ៉ាងខ្លាំង ហាក់ដូចជាអស់កំលាំង ឃើញដូច្នេះចិត្តមិនដាច់គេក៏បានជួយសង្គ្រោះក្មេងនេះ។ លុះព្រឹកឡើងថ្ងៃទី១៧ សីហា ២០០៥ វេលាម៉ោង៩ព្រឹក ពួកគេទាំងពីរនាក់នាំយកក្មេងដ៏កំសត់ទៅប្រគល់ជូនបុរីកុមារកំព្រាបាត់ដំបង១ ដែលមានទីតាំងផ្លូវចូលតាមវត្តពោធិវង្ស និងនៅខាងជើងវិទ្យុខេមរាFM91ដើម្បីចិញ្ចឹមបីបាច់ថែរក្សាក្មេងនោះឱ្យមានជីវិតរស់បន្តទៅមុខទៀត។

បើតាមផ្លូវច្បាប់រាល់អាណាព្យាបាលដែលគ្មានភាពទទួលខុសត្រូវយកកូនរបស់ខ្លួនមកបោះបង់ចោលរបៀបនេះត្រូវទទួលទោសតាមផ្លូវច្បាប់ជាកំហិត មិនតែប៉ុណ្ណោះអ្នកនោះបានបង្កការលំបាកដល់អ្នកដទៃទៀតផង៕

*ដកស្រង់ចេញពី កម្ពុជាថ្មី លេខ៨១៥*
*ថ្ងៃទី២០_០៨_០៥*

# ជនជាតិភាគតិចរស់នៅមណ្ឌលគិរីភាគច្រើនរៀនត្រឹមថ្នាក់បឋមសិក្សា

នាយកមន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរីបាននិយាយថា កុមារជនជាតិភាគតិចដែលរស់នៅខេត្តមណ្ឌលគិរីភាគច្រើនរៀនត្រឹមថ្នាក់បឋមសិក្សាដោយសារភាពក្រីក្រនៅក្នុងគ្រួសារ។

លោកទឹម សង្វាតបានប្រាប់កម្ពុជាថ្មីថា នៅក្នុងខេត្តរបស់គាត់មានជនជាតិភាគតិចរស់នៅចំនួន៩ជនជាតិ ហើយកុមារដែលជាកូនចៅរបស់ជនជាតិទាំងនោះភាគច្រើនរៀនចប់ត្រឹមបឋមសិក្សាដោយសារជីវភាពគ្រួសារមានការខ្វះខាត ហើយម្យ៉ាងទៀតសាលានៅឆ្ងាយពីភូមិរបស់គេ។ មានកុមារមួយចំនួនរៀនចប់ថ្នាក់ទី៩ និងមួយចំនួនតូចរៀនចប់ថ្នាក់ទី១២។

លោកទឹម សង្វាតបានឱ្យដឹងទៀតថា កុមារជនជាតិភាគតិចភាគច្រើនចូលរៀននៅអាយុពី៨ទៅ១២ឆ្នាំ។ លុះដល់ពួកគេរៀនចប់បឋមសិក្សាពួកគេមានអាយុកាន់តែច្រើន(ពេញវ័យ)ដែលអាចមានលទ្ធភាពជួយធ្វើការងារក្នុងគ្រួសារបាន និងដល់អាយុដែលត្រូវមានគូស្រករផងដែរ ព្រោះជនជាតិភាគតិចរៀបការនៅអាយុពី១៤ទៅ១៥ឆ្នាំសំរាប់មនុស្សស្រី បើបុរសពី១៨ទៅ២០ឆ្នាំ។ ដោយសារតែកត្តាអាយុ ភាពក្រីក្រក្នុងគ្រួសារ ហើយគួបផ្សំនឹងសាលារៀននៅឆ្ងាយទៀតនោះបានតំរូវឱ្យជនជាតិភាគតិចភាគច្រើនរៀនចប់ត្រឹមបឋមសិក្សា។

លោកបាននិយាយបន្ថែមទៀតថា ចំពោះកុមារដែលរៀនចប់ថ្នាក់ទី៩ និងទី១២ គឺដោយសារមានអាហារូបករណ៍ដែលក្រសួងអប់រំផ្តល់ឱ្យដែលជាការឧបត្ថម្ភពីអង្គការជប៉ុន និងអង្គការCCIរបស់សហរដ្ឋអាមេរិក។ លោកនិយាយថា អង្គការរបស់ជប៉ុននេះជួយទៅលើកុមារជនជាតិភាគតិច ដោយជួយឧបត្ថម្ភពីថ្នាក់ទី៧ដល់ទី៩។ ចំណែកអង្គការCCIរបស់សហរដ្ឋអាមេរិកវិញជួយទាំងកុមារក្រីក្រខ្មែរ និងជនជាតិដែលជួយចាប់ពីបឋមសិក្សាទៅដល់ថ្នាក់ឧត្តមសិក្សា។ បច្ចុប្បន្ននេះមាននិស្សិតចំនួន៦នាក់ហើយដែលកំពុងសិក្សាថ្នាក់ឧត្តមសិក្សានៅភ្នំពេញ។

លោកបញ្ជាក់ថា អង្គការCCI ជួយក្នុងមួយឆ្នាំ១៥០នាក់ដោយផ្តល់ជាម្ហូបអាហារ សំលៀកបំពាក់ និងឧបករណ៍សិក្សាជាដើម។ ចំណែកក្រសួងអប់រំជួយផ្តល់អន្តេវាសិកដ្ឋានសំរាប់ឱ្យកុមារ និងនិស្សិតទាំងនោះស្នាក់នៅ និងផ្តល់ថវិកាចំនួន១០០០រៀលក្នុងមួយថ្ងៃ

ហើយក្នុងមួយឆ្នាំក្រសួងទិញសំលៀកបំពាក់ និងសំភារៈសិក្សាសំរាប់ពួកគេផងដែរ។ រីឯអង្គការ CCI ក៏បានជីកអណ្តូង និងផ្តល់ជាសត្វមាន់ និងជ្រូកដើម្បីឱ្យសិស្សចិញ្ចឹមនៅក្នុងអន្តេវាសិកដ្ឋានសំរាប់ផ្គត់ផ្គង់ម្ហូបអាហារប្រចាំថ្ងៃ។

លោកទឹម សង្វាតបាននិយាយទៀតថា ដោយសារតែមានអង្គការជួយផ្តល់អាហារូបករណ៍ដល់សិស្សដែលជាជនជាតិភាគតិច ឬសិស្សក្រីក្រនេះហើយទើបធ្វើឱ្យពួកគេមានលទ្ធភាពសិក្សាបានខ្ពស់ជាងមុន។ ប្រសិនបើមិនមានការផ្តល់អាហារូបករណ៍ដល់ពួកគេទេ ពួកគេត្រូវឈប់រៀនទៅធ្វើស្រែចំការ ឬយកគូស្រករ៕

*ដកស្រង់ចេញពី កម្ពុជាថ្មី លេខ៨១៦*
*ថ្ងៃទី២១_២២ សីហា ០៥*

# កុមារនៅភូមិឡុមិនមានសាលាសំរាប់ចូលរៀន

កុមារតូចៗរស់នៅភូមិឡុ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មិនមានសាលាសមរម្យសំរាប់ចូលរៀននៅឡើយ ដែលទាមទារឱ្យក្រសួងអប់រំសម្លឹងឱ្យបានមុតជាងនេះ ដើម្បីសំរេចនូវគោលដៅអប់រំសំរាប់ទាំងអស់គ្នា។

លោកសាន រឿន អនុប្រធានភូមិឡុ ឃុំត្រែងត្រយឹង បានប្រាប់រស្មីកម្ពុជាឱ្យដឹងនៅថ្ងៃទី២១សីហា ២០០៥កន្លងមកនេះថា ភូមិឡុមានប្រជាពលរដ្ឋរស់នៅចំនួន៧៦គ្រួសារ មានកុមារដល់វ័យចូលរៀនជាង៨០នាក់។ សាលារៀននៅក្នុងភូមិកសាងឡើងដោយសហគមន៍ក្នុងភូមិផ្ទាល់ ដែលមានតែមួយបន្ទប់សំរាប់សិស្សានុសិស្សជាង៨០នាក់។ ថ្នាក់រៀននេះមានសិស្សរៀនពីរកម្រិតនៅជាមួយគ្នា គឺថ្នាក់ទី១និងទី២ បន្ទប់រៀនត្រូវចែកមួយចំហៀងម្នាក់។

លោកសាន រឿន បានបន្តឱ្យដឹងថា សាលារៀនដែលសាងសង់ដោយមាតាបិតាសិស្សនេះមានតែដំបូលឥតជញ្ជាំង ពេលភ្លៀងខ្លាំងសិស្សានុសិស្សមិនអាចរៀនបានឡើយ។ លោកបន្តថា គ្រូបង្រៀននៅទីនេះជាគ្រូស្ម័គ្រចិត្តប្រចាំភូមិ ដែលអ្នកភូមិជួលឱ្យជួយបង្រៀនកូនរបស់ពួកគាត់។ លោកគ្រូយកកម្រៃពីសិស្សម្នាក់ចំនួន២០០រៀលក្នុងមួយពេល ប៉ុន្តែបើគ្រួសារណាមានកូនពីរនាក់មកចូលរៀន គឺលោកគ្រូយកតែបីរយរៀលប៉ុណ្ណោះ។

លោកមេភូមិឡុ បានបន្តឱ្យដឹងទៀតថា ពីមុនមានគណបក្សនយោបាយមកឃោសនានៅពេលបោះឆ្នោតជាប់ឬមិនជាប់ក៏សង់សាលាឱ្យភូមិនេះដែរ ប៉ុន្តែក្រោយពេលជាប់ឆ្នោតមិនឃើញគណបក្សនោះមកសង់សាលាឱ្យភូមិទេ គឺបានត្រឹមតែសន្យា ឯគណបក្សមិនជាប់ឆ្នោតក៏មិនឃើញមកសាងសង់សាលារៀនឱ្យភូមិនេះដែរ។ លោកបន្តថា ភូមិនេះពីមុនមានប្រជាជនរស់នៅ៨០គ្រួសារ ប៉ុន្តែដោយលំបាកផ្នែកជីវភាព និងមិនមានសាលាសំរាប់កូនរៀន ពួកគេក៏បានចាកចេញទៅរស់នៅកន្លែងផ្សេងមួយចំនួនហើយ។ លោកបន្តថា ពេលនេះអ្នកភូមិចង់បានសាលារៀនមួយខ្នង មានអណ្តូងទឹកប្រើប្រាស់ មានគ្រូដែលទទួលប្រាក់ខែពីក្រសួងអប់រំមកបង្រៀននៅទីនេះ ប៉ុន្តែការទន្ទឹងចាំផ្លូវពីសប្បុរសជន ពីក្រសួងអប់រំក៏ចេះតែស្ងាត់ទៅៗ សូម្បីស្រមោលក៏មិនឃើញផង។

លោកសាន រឿន បានបន្តថា ពេលនេះឱ្យតែមានអ្នកណាមកសាងសង់សាលារៀនឱ្យកុមារនៅទីនេះ យើងមានដី២ហិចតាដែលផ្តល់ដោយមន្ត្រីម្នាក់សម្រាប់សាងសង់អគារសិក្សាបានភ្លាម ហើយអ្នកផ្តល់ដីនោះរីករាយនឹងផ្តល់ដីសំរាប់សហគមន៍ទៀតផង។ អ្នកមីងបាន ចំរើន មានប្រសាសន៍ថា អ្នកភូមិតែងចង់បានសាលាឱ្យកូនរៀនបានត្រឹមត្រូវ ដើម្បីឱ្យមានចំណេះដឹងកុំឱ្យលំបាកដូចពួកគាត់។ ប្រជាជនភូមិឡុគឺជាអ្នកចំណូលថ្មីមកពីខេត្តឆ្ងាយៗ មករស់នៅទីនេះលើទំហំដីទទឹង២០ម៉ែត្រនិងបណ្តោយ៣០ម៉ែត្រដែលរដ្ឋបានផ្តល់ឱ្យ។ អ្នកមីងបានបន្តថា ភូមិនេះវានៅជិតជើងភ្នំគិរីរម្យតែវាហាក់ឆ្ងាយដូចជើងមេឃ ដែលគេមិនមើលឃើញពីទុក្ខលំបាករបស់ពួកគាត់។

អ្នកមីងបាន ចំរើន បន្តទៀតថា ទោះបីការងាររបស់បងប្អូននៅភូមិនេះរកមុខខ្វះក្រោយ រកក្រោយខ្វះមុខយ៉ាងណាក៏ដោយ ក៏ពួកគាត់នៅតែត្រដរបេះពីមាត់យកលុយឱ្យកូនបង់ឱ្យគ្រូដើម្បីចូលរៀន។ លោកគ្រូនោះក៏មានជីវភាពលំបាកលំបិនខ្លាំងណាស់ដែរ ជួនកាលគាត់ដាច់បាយ អ្នកភូមិក៏ហុចបាយសម្លជូនគាត់ពិសារខ្លះៗតាមដែលអាចជួយបាន។ អ្នកមីងបានបន្តថា ពេលនេះអ្នកណាក៏ដោយ

ដែលមានចិត្តសប្បុរសសូមជួយសង់សាលារៀនឱ្យភូមិគាត់ ដើម្បីឱ្យកូនៗរបស់គាត់មានអនាគតភ្លឺស្វាងនឹងគេផង កុំឱ្យមិនចេះអក្សរដូចពួកគាត់ គឺពិបាកណាស់។

លោកសាន រឿន បានបន្តថា ប្រជាជនភូមិឡតែងដាច់បាយរៀងរាល់ឆ្នាំ ព្រោះពួកគាត់បង្កបង្កើនផលមិនបាន ដោយសារមិនមានដីដាំដំណាំ។ ប្រជាជនខ្លះស៊ីឈ្នួលកាប់ចំការឱ្យគេ ឬធ្វើស្រែលើដីគេទំនេរទុកចោលប្រមូលយកបានផលដោយខ្លួនឯង។ ពិសេសរដូវប្រាំង ពិបាករកទឹកប្រើប្រាស់ណាស់ព្រោះអ្នកភូមិមិនមានអណ្តូងទេ។ ពេលរដូវវស្សាគ្រប់ក្រុមគ្រួសារតែងមានអ្នកឈឺដោយជំងឺគ្រុនចាញ់៕

*ដកស្រង់ចេញពី រស្មីកម្ពុជា លេខ៣៧៦០*
*ថ្ងៃទី២៣_០៨_០៥*

# បីឆ្នាំចុងក្រោយនេះស្ត្រីខ្មែរគេជួញដូរនៅម៉ាឡេស៊ី

លោកស្រីអ៊ុង ច័ន្ទថុលថ្លែងថា ការជួញដូរមនុស្សពីកម្ពុជាទៅម៉ាឡេស៊ីគឺជាព្រឹត្តិការណ៍ថ្មីមួយដែលទើបនឹងកើតមានក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ។

លោកស្រីបញ្ជាក់ទៀតថាហេតុការណ៍នេះបានកើតឡើងបន្ទាប់ពីស្ត្រីជាច្រើនដែលរងគ្រោះផ្ទាល់បានទូរស័ព្ទពីប្រទេសម៉ាឡេស៊ីមកសុំឱ្យអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិជួយដល់ពួកគេ និងក្រុមគ្រួសារជនរងគ្រោះខ្លះក៏បានប្តឹងមកអង្គការនេះផងដែរ ដើម្បីសុំឱ្យជួយពីការបាត់ខ្លួនរបស់កូនស្រី ខណៈពេលដែលពួកគេត្រូវបានគេនាំខ្លួនទៅរកការងារធ្វើនៅប្រទេសម៉ាឡេស៊ី។ តែតាមពិតពួកគេត្រូវចាញ់បោកក្នុងការជួញដូរឱ្យធ្វើជាពេស្យាចារ និងធ្វើការងារផ្សេងៗដែលមិនបានទទួលកំរៃក្រោមលក្ខខណ្ឌដ៏លំបាកបំផុតនៅប្រទេសម៉ាឡេស៊ី។

លោកស្រីអ៊ុង ច័ន្ទថុល នាយិកាប្រតិបត្តិនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានថ្លែងបែបនេះ នៅក្នុងសិក្ខាសាលាស្តីពីការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវអំពីការជួញដូរស្ត្រី និងកុមារកម្ពុជាទៅប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី១៨ សីហា នៅឯសាលសន្និសីទនៃអង្គការទស្សនៈពិភពលោក ដែលសិក្ខាសាលានេះរៀបចំដោយអង្គការនេះ។

លោកស្រីបន្តថា នៅចុងឆ្នាំ២០០៤ បុគ្គលិកអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានរួមដំណើរជាមួយនឹងអង្គការផ្សេងៗទៀតមួយក្រុមទៅបំពេញទស្សនកិច្ចសិក្សានៅប្រទេសម៉ាឡេស៊ី ដោយបានចុះជួបជាមួយស្ត្រីខ្មែរដែលធ្វើការនៅទីនោះ និងចុះទៅពិនិត្យមើលជំរុំរបស់ពលករខ្មែរដែលធ្វើការជាជាងសំណង់ខុសច្បាប់នៅទីនោះ ហើយបានព័ត៌មានជាច្រើនទាក់ទងនឹងការជួញដូរស្ត្រី និងកុមារកម្ពុជានៅប្រទេសម៉ាឡេស៊ី។ ដោយសារបញ្ហានេះជាបញ្ហាធ្ងន់ធ្ងរ និងមិនទាន់មានការសិក្សាស្រាវជ្រាវណាមួយដែលជាក់លាក់នៅឡើយនោះ ទើបជំរុញឱ្យអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិធ្វើការស្រាវជ្រាវអំពីបញ្ហានេះឡើងវិញ ក្នុងគោលបំណងដើម្បីប៉ាន់ស្មានលើលក្ខខណ្ឌ និងទំហំនៃការជួញដូរស្ត្រី និងកុមារពីប្រទេសកម្ពុជាទៅប្រទេសម៉ាឡេស៊ី និងដើម្បីកំណត់អនុសាសន៍សំរាប់សហការនៅថ្ងៃអនាគត។

លោកស្រីសង្ឃឹមថា រដ្ឋាភិបាលម៉ាឡេស៊ី និងរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាអង្គការសង្គមស៊ីវិលដទៃទៀតរបស់ប្រទេសទាំងពីរនេះនឹងបន្តជួយជនរងគ្រោះរីតតែសកម្មឡើងដោយផ្តន្ទាទោសដល់ជនល្មើស ផ្សព្វផ្សាយទប់ស្កាត់ និងធ្វើការបែងចែករវាងជនរងគ្រោះដោយការជួញដូរ និងជនអន្តោប្រវេសន៍ខុសច្បាប់ឱ្យបានច្បាស់លាស់។

ព័ត៌មានដែលបានរៀបរាប់ខាងលើនេះដកស្រង់ចេញពីកាសែតកោះសន្តិភាព លេខ៩៥០៩ ចុះថ្ងៃទី១៩ សីហា ២០០៥។

ចំណែកឯកាសែតរស្មីកម្ពុជា លេខ៣៧៥៨ ចេញផ្សាយកាលពីថ្ងៃទី២០សីហា ២០០៥កន្លងទៅនេះបានឱ្យដឹងថា នៅក្នុងខ្សែអាត់សំលេងដែលបានចាក់ផ្សាយក្នុងអង្គសិក្ខាសាលា កុមារី វ.ស អាយុ១៥ឆ្នាំ បានរៀបរាប់ថា ខ្លួននាងផ្ទាល់ជាមួយបងស្រីបង្កើតត្រូវបានមេខ្យល់ម្នាក់និយាយបញ្ចុះបញ្ចូលឱ្យទៅធ្វើការងារនៅប្រទេសម៉ាឡេស៊ីជាអ្នកបំរើក្នុងហាង។ ដោយសារការជឿទុកចិត្តគេ ទើបរូបនាង និងបងស្រីយល់ព្រមតាមការល្បួងលោមរបស់មេខ្យល់។

នាងវ.សបន្តថា ការចេញទៅធ្វើការនៅប្រទេសម៉ាឡេស៊ីនេះ ត្រូវធ្វើដំណើររបៀបលួចលាក់តាមរថយន្តពីច្រកប៉ោយប៉ែត ផ្សារឡុងក៏ ដែលត្រូវឆ្លងកាត់ និងស្នាក់នៅប្រទេសថៃចំនួន២ថ្ងៃ ទើបទៅដល់ទ្រេសម៉ាឡេស៊ី។

ខណៈពេលទៅដល់ប្រទេសម៉ាឡេស៊ី រូបនាង និងបងស្រីរួមជាមួយស្ត្រីខ្មែរ២នាក់ផ្សេងទៀតដែលបានទៅដល់២ថ្ងៃមុននោះ ត្រូវបានម្ចាស់ផ្ទះបង្ខំឱ្យទទួលភ្ញៀវប្រុសៗ ដើម្បីបំរើផ្លូវភេទនៅហាងខារ៉ាអូខេមួយ។

បន្ទាប់ពីធ្លាក់ខ្លួនជានារីរកស៊ីផ្លូវភេទ ដែលត្រូវទទួលភ្ញៀវចំនួន៤នាក់ក្នុងមួយថ្ងៃ ដោយសារតែការចាញ់បោកមេខ្យល់រយៈពេលជិតមួយខែរួចមក ទើបនារីរងគ្រោះទាំងអស់នេះបានរំដោះខ្លួនចេញរួចផុតពីកន្លែងឃុំឃាំងនោះ។ ការរួចផុតពីកន្លែងនោះ គឺដោយសារមានការជួយជ្រោមជ្រែង និងអន្តរាគមន៍ពីស្ថានទូតខ្មែរប្រចាំនៅប្រទេសម៉ាឡេស៊ី អង្គការក្រៅរដ្ឋាភិបាលនៅម៉ាឡេស៊ី និងរួមទាំងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិផងដែរ។

លោកស្រីសាន្ត អារុណ អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារីមានប្រសាសន៍ថា គិតចាប់ពីឆ្នាំ២០០៣រហូតមកទល់ពេលនេះ មានស្ត្រីរងគ្រោះដោយសារការជួញដូរផ្លូវភេទនៅប្រទេសម៉ាឡេស៊ីចំនួន៣៦នាក់ហើយ។ ដោយឡែកនៅឆ្នាំ២០០៥នេះ មាន៣ករណីដែលមានស្ត្រីរងគ្រោះចំនួន១៩នាក់ត្រូវបានជួយរំដោះឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ៕

## គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ
## NGO Committee on the Rights of the Child

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(គ.អ.ស.ក)ជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលមួយដែលមានអង្គការជាសមាជិកចំនួន៤០។ គ.អ.ស.ក មានតួនាទីធ្វើការលើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ ធ្វើការងារតស៊ូមតិ និងតាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។

ដោយយល់ឃើញពីតំរូវការចាំបាច់នៃការប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយព័ត៌មាននានាដែលទាក់ទងនឹងកុមារនៅក្នុងប្រទេសកម្ពុជា ទើបគ.អ.ស.ករៀបចំសំរង់ព័ត៌មានប្រចាំសប្តាហ៍នេះដែលជាការដកស្រង់ពត៌មានទាក់ទងនឹងកុមារពីអត្ថបទនៃបណ្តាសារព័ត៌មាននានាដែលវាពុំមែនជាគំនិត ឬទស្សនៈរបស់គ.អ.ស.កទេ។

អាសយដ្ឋានទំនាក់ទំនង: ផ្ទះកុមារ លេខ៨A ផ្លូវ១៣៨ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ២៣ ៨៨២ ៤១២

ទូរសារ : (៨៥៥) ២៣ ៨៨២ ៤១២

អ៊ីមែល : ch.ngocrc@online.com.kh